រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

019KH01A-01

ការចែកចាយសេចក្តីស្រឡាញ់ ដល់អ្នកជឿថ្មី



កូនស្បៀរភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

១៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

មែនហើយបួ ! ព្រះជាម្ចាស់ស្រឡាញ់ប្អូន ហើយយើងក៏ស្រឡាញ់ប្អូនដែរ ។ យើងនឹងជួយប្អូនឲ្យរៀបចំជីវិតថ្មី គឺអ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ ។ ប្អូនបានកែប្រែចិត្តគំនិត និងទទួលជឿព្រះយេស៊ូគ្រីស្ត ក៏ប៉ុន្តែ ប្អូននៅមិនទាន់ទទួលពិធីជ្រមុជទឹកនៅឡើយ ។ ខ្ញុំនឹងធ្វើពិធីជ្រមុជទឹកអោយប្អូននៅថ្ងៃអាទិត្យនេះ ។ ហើយយើងអញ្ជើញប្អូនអោយធ្វើជាសមាជិករបស់ក្រុមជំនុំយើង ។



(សម្លេងខ្សឹប)...មើលទៅ អ្នកជឿថ្មីម្នាក់នោះធុំក្លិនស្អុយណាស់ ! មើលខោអាវគ្រែចក្រខ្វក់របស់វាចុះ ។ គួរអោយខ្មាស់គេណាស់ !



(កិច្ចការ ២:៣៧-៤២, ៨:៣៥-៣៩, ១៦:១៤-១៥ និង ១៦:៣០-៣៤)

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ទន្ទេញ ភីលីព ១:៦ អោយចាំស្មាត់ក្នុងចិត្ត ។

- តែងតាំងសមាជិកក្រុមជំនុំណាម្នាក់ អោយទទួលពួកអ្នកជឿថ្មី និងភ្ញៀវនៅពេលប្រជុំថ្វាយបង្គំ ។ សមាជិកនោះត្រូវចេះណែនាំអ្នកថ្មីអោយជួបស្គាល់អ្នកជឿឯទៀត ។

- ទៅសួរសុខទុក្ខពួកអ្នកជឿថ្មី ។

- បើសិនជាក្រុមជំនុំធំពេក ហើយខ្លួនអ្នកផ្ទាល់មិនអាចមានពេលទៅសួរសុខទុក្ខ សូមចាត់តាំង «បងប្អូនចាស់ទុំ» ម្នាក់អោយទៅសួរសុខទុក្ខអ្នកជឿថ្មីម្នាក់ ។ បងប្អូនចាស់ទុំនោះត្រូវទទួលខុសត្រូវក្នុងការជួយអ្នកជឿថ្មីនោះ ខាងជីវិតថ្មីជាគ្រីស្តបរិស័ទរបស់គេ ។ បងប្អូនចាស់ទុំនោះ ត្រូវរៀបចំឱ្យអ្នកជឿថ្មីបានទទួលពិធីជ្រមុជទឹក បង្រៀនគេអោយចេះអធិស្ឋាន និងចេះប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត ។

ពិធីជ្រមុជទឹកមិនមែនជាការជូនសញ្ញាប័ត្រដល់អ្នកបរិសុទ្ធដែលបានរៀនចប់វគ្គសិក្សាអំពីគោលលទ្ធិនោះទេ ។ ពិធីនេះ គឺសំរាប់ធ្វើអោយអ្នកមានបាប ដែលបានកែប្រែចិត្តគំនិត និងជឿលើព្រះគ្រីស្តវិញទេ ។ ពិធីនេះជាជំហានដំបូងរបស់គាត់ ។ សូមប្អូនស្រីអានម៉ាថាយ ២៨:១៨-២០ចុះ ។





២- ចូរយើងចេះទុកចិត្តថា ព្រះជាម្ចាស់ដែលបានចាប់ផ្តើមធ្វើ
ការល្អក្នុងចិត្តពួកអ្នកជឿថ្មី ព្រះអង្គក៏នឹងធ្វើរហូតដល់ចប់
សព្វគ្រប់ដែរ ។ ព្រោះបើយើងសង្ស័យ នោះយើងនឹងធ្វើឱ្យ
ពួកអ្នកជឿថ្មីធ្លាក់ទឹកចិត្តមិនខាន ។

តើយើងត្រូវទទួលពួកអ្នកជឿថ្មី ដោយអាកប្បកិរិយារបៀប
ណា ?

៣- បួបានខិតខំនាំគ្រួសាររបស់គាត់មកថ្វាយព្រះជាម្ចាស់ ។
ក្រុមជំនុំ ដែលមានក្រុមគ្រួសារទាំងមូលជាច្រើនចូលជា
សមាជិក ជាក្រុមជំនុំរឹងមាំ ។ តើអ្នកនឹងជួយពួកអ្នកជឿថ្មី
អោយអាចនាំក្រុមគ្រួសាររបស់ពួកគេ មកថ្វាយព្រះជាម្ចាស់
ដែរឬទេ ?

© Project WorldReach © SEAN



(យ៉ាកុប ៤:៧)

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ពួកសាវ័កតែងតែទទួលពួកអ្នកជឿ ដែលកែប្រែចិត្តគំនិត ជាសមាជិកក្នុងគ្រួសាររបស់ព្រះជាម្ចាស់ជានិច្ច ។

បើសិនជាយើងសង្ស័យថា មនុស្សមិនទាន់បានសង្គ្រោះពិតប្រាកដទេនោះ យើងត្រូវ :

☐ ណែនាំ និងលើកទឹកចិត្តពួកគេថែមទៀត ។

☐ ធ្វើអោយពួកគេធ្លាក់ទឹកចិត្ត ។



ខ្ញុំជាសមាជិករបស់ក្រុមជំនុំនេះម្ភៃឆ្នាំមកហើយ ។ តើលោកគ្រូចង់និយាយថា បូដែលទើបនឹងមកថ្មីនេះ ហើយដែលពីមុនធ្លាប់ជាមនុស្សប្រមឹក ត្រូវមានសិទ្ធិចូលរួមនៅក្នុងក្រុមជំនុំដូចខ្ញុំដែរឬ ?



ត្រូវហើយបូផា ។ ខ្ញុំនឹងនិយាយប្រាប់ប្អូនស្រីពីប្រស្នាអំពីកម្មករចំការទំពាំងបាយជូរ ។ នៅក្នុងប្រស្នានោះ ព្រះអម្ចាស់ពន្យល់យើងអំពីរបៀប ដែលយើងត្រូវប្រព្រឹត្តចំពោះបងប្អូនយើងក្នុងព្រះគ្រីស្ទ ។

“ម្ចាស់ចំការម្នាក់ចេញពីផ្ទះតាំងពីព្រលឹម ដើម្បីរកជួលកម្មករមកបេះផ្លែទំពាំងបាយជូរក្នុងចំការរបស់គាត់...។

ក្រោយមក ...

អរគុណលោកគ្រូ ដែលបានជួយខ្ញុំអោយចេះទុកចិត្តថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើការក្នុងចិត្តរបស់បូ ។ ពិតជាអស្ចារ្យមែន ! បូបាននាំទាំងក្រុមគ្រួសាររបស់គាត់មកថ្វាយព្រះអម្ចាស់ទៀតផង ។



ថែមទាំងបងប្អូនជីដូនមួយរបស់ខ្ញុំប្រាំនាក់ និងគ្រួសាររបស់ពួកគេទៀត ។ រួចឥឡូវនេះ ខ្ញុំមានការទទួលខុសត្រូវលើជីវិតខ្លួនឯង ហើយរស់នៅត្រឹមត្រូវហើយ !

© Project WorldReach © SEAN

ខ្ញុំនឹងអោយប្រាក់អ្នកមួយដួងក្នុងមួយថ្ងៃ ។



យល់ព្រម តោះពួកយើងនាំគ្នាទៅធ្វើការ ។

(ម៉ាថាយ ២០:១-២)

* ប្រាក់មួយដួងជាថ្លៃឈ្នួល ដែលកម្មករទទួល សំរាប់ការងារពេញមួយថៃ នៅក្នុងសម័យកាលជនជាតិរ៉ូម៉ាំង ។

ប៉ុន្តែ ពួកយើងបានសិក្សាព្រះគម្ពីរច្រើនណាស់ ហើយបានរងទុក្ខលំបាក ដើម្បីព្រះគ្រីស្តច្រើនណាស់ដែរណា៎ ។ យើងកសាងបានព្រះវិហារដ៏ល្អ ហើយលោកគ្រូចង់ទទួលពួកមនុស្សថ្មីទាំងនេះ ដោយគ្មានអោយពួកគេធ្វើអ្វីទាំងអស់អញ្ចឹងឬ ! រួចឱ្យពួកគេមានសិទ្ធិក្នុងក្រុមជំនុំ ដូចសមាជិកឯទៀតៗផង ។



មែនហើយ ! យើងដែលជាសមាជិកចាស់ទុំ គួរតែសប្បាយរីករាយ ដោយឃើញមានអ្នកជឿថ្មីមកចូលរួមជាមួយយើងទៅវិញទេ ។ ព្រះយេស៊ូគ្រីស្តមានព្រះបន្ទូលថា៖ *“អ្នកដែលនៅខាងមុខ នឹងត្រឡប់ទៅនៅខាងក្រោយ ឯអ្នកដែលនៅខាងក្រោយ នឹងត្រឡប់ទៅនៅខាងមុខវិញ”* (ម៉ាថាយ ២០:១៦) ។

ប្រមាណជាម៉ោងប្រាំបួនព្រឹក ម្ចាស់ចំការចេញទៅ ឃើញអ្នកផ្សេងទៀត កំពុងតែឈរនៅតាមទីផ្សារ ឥតធ្វើអ្វីសោះ ។...

ម្ចាស់ចំការចេញទៅសាជាថ្មីទៀត នៅម៉ោងដប់ពីរ ម៉ោងបីរសៀល និង ម៉ោងប្រាំលាច ដើម្បីជួលអ្នកផ្សេងតាមរបៀបដដែល ។...

(ម៉ាថាយ ២០:៣-៧)



នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ពួកអ្នកជឿថ្មីមានសិទ្ធិដូចពួកអ្នកដែលជឿមុនដែរ ពីព្រោះយើងទាំងអស់គ្នាសុទ្ធតែបានសង្គ្រោះ តែដោយសារព្រះហឫទ័យប្រណីសន្តោស និងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ។



លុះដល់លាច ម្ចាស់ចំការអោយប្រាក់មួយដួងទៅពួកអ្នកដែលមកធ្វើការក្រោយគេ ។...



(ម៉ាថាយ ២០:៨-១០)

ពួកអ្នកដែលចាប់ផ្តើមធ្វើការនៅពេលល្ងាចហើយ តំណាងពួកគ្រីស្តជនថ្មី ។ ព្រះគ្រីស្តដែលជាម្ចាស់ចំការចង់ប្រទានអ្វីៗអោយពួកគេ ទោះបីគេមិនសមនឹងទទួលក្តី ។ ពួកគេក៏បានសង្គ្រោះ ដោយសារតែព្រះហឫទ័យប្រណីសន្តោសប៉ុណ្ណោះ ដូចយើងដែរ ។ ប៉ុន្តែ មានពេលខ្លះ សមាជិកចាស់ទុំរបស់ក្រុមជំនុំមានចិត្តច្រណែន បើសិនជាព្រះជាម្ចាស់ប្រទានព្រះគុណឱ្យសមាជិកថ្មីទាំងនោះច្រើនជាង ។



ប៉ុន្តែ ម្ចាស់ចំការអោយប្រាក់ឈ្នួលដូចគ្នាដែរ ទៅពួកអ្នកដែលចាប់ផ្តើមធ្វើការមុនគេ ។...

ពួកអ្នកទាំងនោះមកដល់ក្រោយគេ បានធ្វើការតែបន្តិចប៉ុណ្ណោះ តែលោកអោយប្រាក់ឈ្នួលស្មើនឹងពួកយើងដែលស៊ូទ្រាំនឹងកំដៅថ្ងៃពេញមួយថ្ងៃ និងធ្វើការធ្ងន់ជាងគេទៅរិញ ។



សំឡាញ់អើយ ! ខ្ញុំមិនបានឆោកបញ្ឆោតអ្នកទេ ។ អ្នកបានយល់ព្រមធ្វើការឱ្យខ្ញុំក្នុងតំលៃមួយដួង ក្នុងមួយថ្ងៃមែន ឬមិនមែន ? តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬ ? ឬមួយអ្នកច្រណែនមកពីឃើញខ្ញុំមានចិត្តសប្បុរស ?

(ម៉ាថាយ ២០:១០-១៥)

ពួកអ្នកដែលធ្វើការពេញមួយថ្ងៃនោះ តំណាងអ្នកចាស់ទុំរបស់ក្រុមជំនុំ ។ ពួកគេប្រហែលជាបានធ្វើពលិកម្មច្រើនដើម្បីព្រះអម្ចាស់ ។ ប៉ុន្តែ ពួកគេភ្លេចថា ពីដំបូង ពួកគេបានសង្គ្រោះដោយសារតែព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ។ កាលណោះ ពួកគេមិនបានចេញថ្លៃអ្វីទាំងអស់ ។

